# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៧៩....ស.ស.រ..

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំ និង ចូលរួមពិព័រណ៍ពិភពលោក

~~~~~~~~~~~~~

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## <u>ស ម្រេ ច</u>

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក ។

**ប្រការ ២ :** គណៈកម្មការអន្តរក្រសួងនេះ មានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម **ចម ប្រសិទ្ធ** | រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២-ឯកឧត្តម **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣-ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៤-ឯកឧត្តម **ម៉ៅ ថូរ៉ា** | អគ្គនាយក ក្រសួងពាណិជ្ជកម្ម | សមាជិកអចិន្ត្រៃយ៍ |
| ៥-ឯកឧត្តម **គោស៊ុំ សារឿន** | អគ្គនាយក ក្រសួងទេសចរណ៍ | សមាជិក |
~~~~~~~~~~~~~

| | | |
|---|---|---|
| ៦-ឯកឧត្តម **ហង្ស សុត** | អគ្គនាយក ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | សមាជិក |
| ៧-ឯកឧត្តម **គុំ សារឿន** | អគ្គនាយក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ៨-លោក **ឆេង សារឿន** | អគ្គនាយករង ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩-លោក **ម៉ិន លាង** | អគ្គនាយករង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | សមាជិក |
| ១០-លោក **ស៊ឹម ទ៊ា** | ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ១១- លោក **ង៉ាត សុខុម** | ប្រធាននាយកដ្ឋានទីផ្សារ និង ផ្សព្វផ្សាយ ក្រសួងទេសចរណ៍ | សមាជិក |
| ១២-លោក **ទ្រាក់ នត** | ប្រធាននាយកដ្ឋានជំរុញការនាំចេញ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៣-លោក **ញាណ ទិមុល** | អនុប្រធាននាយកដ្ឋានអាស៊ាន ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៤-លោក **ស៊ីន សុថា** | អនុប្រធាននាយកដ្ឋានជំរុញការនាំចេញ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៥-លោក **អៀង ស៊ុនលី** | អនុប្រធាននាយកដ្ឋានថវិកានិយតកម្ម និង ហិរញ្ញកិច្ច ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១៦-លោក **ហេង សោភ័ណ្ឌ** | អនុប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | សមាជិក |
| ១៧-លោក **ជា គៀត** | អនុប្រធាននាយកដ្ឋានទំនាក់ទំនងសាធារណៈ និង ជំរុញវិនិយោគឯកជន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |

**ប្រការ ៣ :** គណៈកម្មការអន្តរក្រសួងនេះ មានភារៈកិច្ចដូចតទៅ:

-ចូលរួមពិព័រណ៍ពិភពលោក នៅទីក្រុងណាហ្គោយ៉ា នៃប្រទេសជប៉ុន ពិព័រណ៍ ២០០៥ អាយជី ក៏ដូចជាពិព័រណ៍អន្តរជាតិ និង ពិព័រណ៍ពិភពលោកបន្តបន្ទាប់ ដើម្បីបំរើការតាំងពិព័រណ៍ពិភពលោក នៃបណ្តាប្រទេសផ្សេងៗ លើពិភពលោក ។

-ធ្វើទំនាក់ទំនងជាមួយភាគីម្ចាស់ផ្ទះ ដើម្បីចូលរួមពិព័រណ៍អន្តរជាតិ និង ពិព័រណ៍ពិភពលោក

-ធ្វើទំនាក់ទំនងជាមួយបណ្តាក្រសួង ស្ថាប័ន អង្គការជាតិ-អន្តរជាតិ និង ក្រុមហ៊ុននានា ដែលពាក់ព័ន្ធដើម្បីត្រៀមលក្ខណៈក្នុងការចូលរួមពិព័រណ៍ពិភពលោក។

-ទទួលខុសត្រូវ និង ចាត់ចែងពីការងាររៀបចំសាងសង់ស្តង់ជាតិ និង សំរបសំរួលការទទួលខុសត្រូវចំពោះស្តង់ផ្នែកឯកជន ។

-ជំរុញការតាំងពិព័រណ៍របស់ព្រះរាជាណាចក្រកម្ពុជាយើង អោយបានទទួលជោគជ័យយ៉ាងត្រចះត្រចង់ នៅទីក្រុងណាហ្គោយ៉ា នៃប្រទេសជប៉ុនខាងមុខនេះ ក៏ដូចជាពិព័រណ៍ពិភពលោកនាឆ្នាំបន្តបន្ទាប់ នៅបណ្តាប្រទេសលើពិភពលោក

4K

-ចូលរួមសន្និសីទ និងសកម្មភាពទាំងឡាយដែលរៀបចំ និងប្រព្រឹត្តទៅរបស់ការិយាល័យរៀបចំពិព័រណ៍អន្តរជាតិ ។

-លើកយោបល់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេចក្នុងករណីចាំបាច់ និង ធ្វើរបាយការណ៍បូកសរុបលទ្ធផលជូនទីស្តីការគណៈរដ្ឋមន្ត្រី និង ក្រសួងពាក់ព័ន្ធ នៅពេលពិព័រណ៍ពិភពលោកមួយលើកៗ ត្រូវបានបញ្ចប់ ។

**ប្រការ ៤ :** នាយកដ្ឋានជំរុញការនាំចេញ នៃក្រសួងពាណិជ្ជកម្ម ជាលេខាធិការដ្ឋាន នៃគណៈកម្មការអន្តរក្រសួងនេះ ដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក ។

**ប្រការ ៥ :** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពិនិត្យ នឹងផ្តល់ថវិកា សំរាប់ចំណាយជូនដល់គណៈប្រតិភូ ដែលត្រូវអញ្ជើញទៅចូលរួម ការតាំងពិព័រណ៍ពិភពលោក ។

**ប្រការ ៦ :** គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការមួយចំនួនសំរាប់ជំនួយការងារ ។

**ប្រការ ៧ :** គណៈកម្មការអន្តរក្រសួងនេះ ត្រូវស្ថិតនៅជានិរន្តន៍ និងមានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងពាណិជ្ជកម្ម ។ សមាជិកគណៈកម្មការអន្តរក្រសួងនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងឈ្មោះក្នុងប្រការ ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៨
- ឯកសារ-កាលប្បវត្តិ